**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋសភា**

លេខ ..៣៦៤០........ .រ.ស.

# សេចក្តីសម្រេច

## ប្រធានរដ្ឋសភា

- **បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា**
- **បានឃើញសេចក្តីសម្រេចលេខ ១៥២/006/២០១៤ កបធ.ច ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៤ របស់ក្រុមប្រឹក្សាធម្មនុញ្ញស្តីពីការពិនិត្យធម្មនុញ្ញភាពលើវិសោធនកម្មជំពូកទី ១២ ប្រការ ៤៨ ថ្មី (ពីរ) នៃបទបញ្ជាផ្ទៃក្នុង នៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា**

## សម្រេច

**ប្រការ ១.**

ប្រកាសឲ្យប្រើវិសោធនកម្មជំពូកទី ១២ ប្រការ ៤៨ ថ្មី (ពីរ) នៃបទបញ្ជាផ្ទៃក្នុង នៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ដែលសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៥ អនុម័តនៅថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៤ ។

**ប្រការ ២.**

សេចក្តីសម្រេចនេះ មានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៤

**ប្រធានរដ្ឋសភា**

**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន**


វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : ( ៨៥៥-២៣ ) ២១៣ ៥៣៥. ២២០ ៦២៨. ទូរសារ : ( ៨៥៥-២៣ ) ២២០ ៦២៩

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រដ្ឋសភា

# វិសោធនកម្មជំពូកទី ១២ ប្រការ ៤៨ ថ្មី (ពីរ) នៃបទបញ្ជាផ្ទៃក្នុង នៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

## ជំពូក និងប្រការតែមួយ.-

បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ជំពូកទី ១២ និងប្រការ ៤៨ ថ្មី (ពីរ) ត្រូវបានកែប្រែដូចតទៅ :

## ជំពូកទី ១២ ថ្មី
## អំពីរបៀបប្រជុំ និងថ្នាក់ដឹកនាំតំណាងរាស្ត្រនៃគណបក្សនយោបាយ

### ប្រការ ៤៨ ថ្មី (ពីរ).-

តំណាងរាស្ត្រនៃគណបក្សនយោបាយ ដែលមានអាសនៈក្នុងរដ្ឋសភា ចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅ ត្រូវរៀបចំថ្នាក់ដឹកនាំតំណាងរាស្ត្រនៃគណបក្សនយោបាយ តាមគណបក្សនយោបាយនីមួយៗ ។ ថ្នាក់ដឹកនាំតំណាងរាស្ត្រនៃគណបក្សនយោបាយ មានសមាសភាពយ៉ាងច្រើន ៣ (បី) រូប ដោយត្រូវមានប្រធាន ១ (មួយ) រូប ។ បញ្ជីរាយនាមរបស់ថ្នាក់ដឹកនាំតំណាងរាស្ត្រនៃគណបក្សនយោបាយត្រូវផ្ញើជូនប្រធានរដ្ឋសភា ។ ថ្នាក់ដឹកនាំតំណាងរាស្ត្រនៃគណបក្សនយោបាយមានភារកិច្ចដូចខាងក្រោម :

-ធ្វើការដឹកនាំតំណាងរាស្ត្ររបស់គណបក្ស ដើម្បីធ្វើឲ្យការងារពាក់ព័ន្ធទាំងឡាយបានប្រព្រឹត្តទៅស្របតាមកម្មវិធីនយោបាយ និងគោលការណ៍នានារបស់គណបក្ស ។

-ធ្វើការសម្របសម្រួលជាមួយថ្នាក់ដឹកនាំតំណាងរាស្ត្រគណបក្សនយោបាយដែលមានអាសនៈក្នុងរដ្ឋសភា ដើម្បីធ្វើឲ្យការងារពាក់ព័ន្ធទាំងឡាយបានប្រព្រឹត្តទៅដោយរលូន និងធានាបាននូវផលប្រយោជន៍របស់ជាតិ និងប្រជាពលរដ្ឋ ។

រដ្ឋសភាត្រូវផ្តល់ឲ្យថ្នាក់ដឹកនាំតំណាងរាស្ត្រនៃគណបក្សនយោបាយ នូវមធ្យោបាយសមស្រប ដើម្បីថ្នាក់ដឹកនាំតំណាងរាស្ត្រនៃគណបក្សនយោបាយ បំពេញតួនាទី និងភារកិច្ចរបស់ខ្លួនបានល្អនៅក្នុងរដ្ឋសភា ។

ប្រធានក្រុមតំណាងរាស្ត្រនៃគណបក្សនយោបាយក្រៅរាជរដ្ឋាភិបាល ដែលមានអាសនៈក្នុងរដ្ឋសភាចាប់ពី ២៥ (ម្ភៃប្រាំ) ភាគរយឡើងទៅ មានឈ្មោះហៅថា ប្រធានក្រុមមតិភាគតិចនៅរដ្ឋសភា ។ ប្រធានក្រុមមតិភាគតិច ជាគូសន្ទនាជាមួយនឹងប្រមុខរាជរដ្ឋាភិបាលទាក់ទងទៅនឹងបញ្ហាប្រទេសជាតិ ។ ប្រធានក្រុមមតិភាគតិច មានឋានៈស្មើនាយករដ្ឋមន្ត្រី ។

អាសនានុក្រមនៃក្រុមតំណាងរាស្ត្រ ត្រូវរៀបជាក្រុមៗតាមគណបក្សនយោបាយពីមុខទៅក្រោយ ។ ក្រុមនីមួយៗ ត្រូវមានសមាជិកយ៉ាងតិចដប់រូប ។ តំណាងរាស្ត្រមួយរូបអាចចូលជាសមាជិករបស់ក្រុមតែមួយប៉ុណ្ណោះ ។ ក្រុមនីមួយៗ ត្រូវមានប្រធានមួយរូប អនុប្រធានមួយរូប ។ គណបក្សនយោបាយណាមានអាសនៈតិចជាងដប់ត្រូវជ្រើសរើសក្រុមណាមួយដែលខ្លួនពេញចិត្តនៅជាមួយ ។ បញ្ជីរាយនាមរបស់ក្រុមតំណាងរាស្ត្រ នៃគណបក្សនយោបាយ ត្រូវផ្ញើជូនប្រធានរដ្ឋសភា ។

វិសោធនកម្មនេះ ត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៤ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៥

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ២០១៤

**ប្រធានរដ្ឋសភា**

**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន**